# ឯកឧត្តម ចម ប្រសិទ្ធ ដឹកនាំគណៈប្រតិភូកម្ពុជា ធ្វើទស្សនៈកិច្ចនៅ ក្រុមហ៊ុនអ៊ីនធើធិក (Intertek) និង ក្រុមហ៊ុនហ៊ាវ៉េ (Huawei) ប្រទេសចិន



នៅក្នុងឱកាសដឹកនាំគណៈប្រតិភូអន្តរក្រសួងកម្ពុជាទៅចូលរួមអបអរទិវាជាតិកម្ពុជា នៅពិព័រណ៍ពិភពលោក នៅទីក្រុងសៀងហៃ ប្រទេសចិន កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធានគណៈកម្មការអន្តរក្រសួង សំរាប់កិច្ចការពិព័រណ៍ពិភពលោក និងជាអគ្គស្នងការ តំណាងកម្ពុជា និងគណប្រតិភូអមដំណើរ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **សុខ ចិន្តា** រដ្ឋមន្ត្រីប្រតិភូអមសម្តេចនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមន្ត្រីអន្តរក្រសួង បានធ្វើទស្សនកិច្ចនៅ **ក្រុមហ៊ុនអ៊ីនធើធិក** (Intertek) នៅទីក្រុងសៀងហៃ ប្រទេសចិន ។

ឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈប្រតិភូអមដំណើរ បានទទួលស្វាគមន៍ដោយ លោក **ថូ យ៉ាវ**(Tau Yao) អនុប្រធានក្រុមហ៊ុនទទួលបន្ទុកផ្នែកទំនិញឧបភោគ លោក **ឃុត សុធី** តំណាងក្រុមហ៊ុន អ៊ីនធើធិក ប្រចាំនៅកម្ពុជា។ គោលបំណងនៃការទស្សនៈកិច្ចនេះគឺដើម្បីស្វែងយល់ពី មន្ទីរពិសោធន៍របស់ក្រុមហ៊ុន និងជួយជាប្រយោជន៍ដល់ ផលិតករកម្ពុជាក្នុងការពង្រឹងសមត្ថភាពនាំចេញតាមតម្រូវការរបស់អ្នកបញ្ជាទិញនៅលើពិភពលោក។ លោក **ថូ យ៉ាវ** បានឱ្យដឹងថា ក្រុមហ៊ុន អ៊ីនធើធិក គឺជាក្រុមហ៊ុនលំដាប់ពិភពលោកនាំមុខគេក្នុងចំណោមក្រុមហ៊ុនធំៗ ៣ ដែលជួយធានាគុណភាព និងសុវត្ថិភាពទំនិញ និងសេវាកម្ម សំរាប់រដ្ឋាភិបាល និងម៉ាកល្បីៗលើពិភពលោក តាមរយៈការពិនិត្យ ការផ្តល់វិញ្ញាបនប័ត្រ ការធ្វើសវនកម្ម ការទទួលការបំរើជូន ក្រុមហ៊ុនផ្សេងៗ ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាល និងការធានារ៉ាប់រងគុណភាព។ ក្រុមហ៊ុនប្រចាំនៅសៀងហៃនេះមាន បុគ្គលិកប្រមាណជាង ២៧00នាក់ ដែលទទួលបន្ទុកពិនិត្យទំនិញវាយនភណ្ឌ ម្ហូបអាហារ និងតុក្កតា។ គួរកត់សំគាល់ថា ក្រុមអ្នក បញ្ជាទិញប្រមាណជា ៥0 ភាគរយ នៅសហរដ្ឋអាមេរិកគឺពឹងផ្អែកលើ ក្រុមហ៊ុនអ៊ីនធើធិក សំរាប់ជាភ្នាក់ងារ ដើម្បី ត្រួតពិនិត្យ គុណភាព និងការធ្វើសវនកម្មលក្ខខ័ណ្ឌការងារ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានមានប្រសាសន៍ថាៈ ដោយកម្ពុជា ជាប្រទេសកំពុង អភិវឌ្ឍន៍

ត្រូវការការជួយជ្រោមជ្រែងផ្នែកសង្វាក់ផលិតកម្មបន្ថែមទៀត ដើម្បីទទួលបានការបញ្ជា ទិញជាពិសេសពីទីផ្សារប្រទេសចិនដែលអនុញ្ញាតិឱ្យកម្ពុជានាំចូលអង្ករដោយរួចពន្ធ និងឱ្យមានការផ្តល់ការបណ្តុះ បណ្តាល និងការធានារ៉ាប់រងគុណភាព ដល់វិស័យវាយនភណ្ឌ និង ទំនិញឧបភោគ បិរភោគរបស់កម្ពុជាផងដែរ។ លោក **ថូ យ៉ាវ** បានសន្យាថានឹងសហការណ៍ជាមួយ រាជរដ្ឋាភិបាលកម្ពុជាដើម្បី ពង្រឹង និងពង្រីកសមត្ថភាព នាំចេញ ដោយបង្កើតឱ្យមានមន្ទីរពិសោធន៏តាមតម្រូវការស្តង់ដា អ្នកបញ្ជាទិញពីកម្ពុជា។ ក្នុងឱកាសនោះដែរថ្នាក់ដឹកនាំក្រុមហ៊ុនអ៊ីនធើធិក ក៏បានបង្ហាញពីមន្ទីរពិសោធន៏ទំនិញឧបភោគបរិភោគ និងវាយនភណ្ឌរបស់ក្រុមហ៊ុនជូនដល់ឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈប្រតិភូកម្ពុជាផងដែរ។

---



ដោយឡែកក្នុងថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងគណៈព្រតីភូអន្តរក្រសួងកម្ពុជាក៏បានទទួលការអញ្ជើញពីសំណាក់ក្រុមហ៊ុន **ហ័រវ៉េ** (Huawei) ដើម្បីធ្វើ ទស្សនៈកិច្ច នៅទីស្នាក់ការកណ្តាលរបស់ ក្រុមហ៊ុន ដែលជាក្រុមហ៊ុនទូរគមនាគមន៏ដ៏ធំមួយនៅលើពិភពលោក នៅទីក្រុង ស៊ីនជើន (Shenzhen) ខេត្ត គ័នតុង (Guangdong) ប្រទេសចិន។ ឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈប្រតិភូអមដំណើរ បានទទួលស្វាគម៏ដោយ លោក **ហ្វីលីព ជ័ង** (Phillips Jiang) អនុប្រធាន ក្រុមហ៊ុនហ័រវ៉េ និងថ្នាក់ដឹកនាំដ៏ទៃទៀត។

គោលបំណងនៃការទស្សនៈកិច្ចនេះគឺដើម្បីស្វែងយល់បន្ថែមពីការធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ័រវ៉េ** ក្នុង វិស័យទូរគមនាគមន៏ និងស្វែងរកកាលានុវត្តភាពដើម្បីពង្រឹង និងពង្រីកវិស័យទូរគមនាគមន៏នៅកម្ពុជា។ តាមរយៈការ ធ្វើបទបង្ហាញរបស់កញ្ញា **ស្រេង ស្រី** អ្នកគ្រប់គ្រងគណនេយ្យក្រុមហ៊ុន **ហ័រវ៉េ** ប្រចាំនៅកម្ពុជា បានបង្ហាញថា: **ហ័រវ៉េ** គឺ ជាក្រុមហ៊ុនធំជាងគេនៅប្រទេសចិនក្នុងវិស័យទូរគមនាគមន៏ ដែលបង្កើតឡើងនៅឆ្នាំ ១៩៨៨ និងជាក្រុមហ៊ុនធំ ជាងគេមួយក្នុងពិភពលោកក្នុងវិស័យនេះ ដែលមានបុគ្គលិកសរុបចំនួនប្រមាណ ៩៥.000 នាក់ ដែលប្រមាណ ៥0 ភាគរយ នៃបុគ្គលិករបស់ខ្លួនផ្តោតទៅលើការស្រាវជ្រាវ និងផលិតកម្ម។ ក្រុមហ៊ុន **ហ័រវ៉េ** មានតំណាងក្រុមហ៊ុន ក្នុងពិភពលោក ចំនួនជាង ១00 ប្រទេស ដែលផ្តោតការធ្វើពាណិជ្ជកម្មទាក់ទងនឹងវិស័យ ទូរគមនាគមន៏របស់ខ្លួនមាន ចំនួន ៤ វិស័យ រួមមានៈ រចនាសម្ព័ន្ធប្រព័ន្ធ

ទូរគមនាគមន៍ កម្មវិធី និង Software សេវាកម្មជំនាញ និងឧបករណ៍។ បន្ថែមលើនេះទៀត លោក **ហ៊ូលីព ជ័ង** មានប្រសាសន៍ជម្រាបជូនគណៈប្រតិភូថាៈ ក្រុមហ៊ុន **ហ័រវ៉េ** គឺជាដៃគូរ សំខាន់សំរាប់ក្រុមហ៊ុន ផ្តល់សេវា ទូរគមនាគមន៍ធំៗ ចំនួន ៤៥ ក្នុងចំណោម ៥០ លើពិភពលោក ហើយក្នុងប្រទេស កម្ពុជា **ហ័រវ៉េ** គឺជាក្រុមហ៊ុននាំមុខគេ ក្នុងការផ្គត់ផ្គង់បរិក្ខារ សំរាប់ជាដំណោះស្រាយ ដល់វិស័យទូរគមនាគមន៍ ដែលបង្កើតតាំងពីឆ្នាំ ១៩៩៩។ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងគណៈប្រតិភូ អន្តរក្រសួងកម្ពុជា ក៏បានលើកឡើងពី ចំណាប់អារម្មណ៍ចំពោះការធ្វើ ពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ័រវ៉េ** ព្រមទាំងវាយ តំលៃខ្ពស់ ចំពោះការ សំរេចបាននេះ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានសំណូមពរឱ្យក្រុមហ៊ុនធ្វើការសហការឱ្យជិតស្និត ជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ដើម្បីពង្រីងវិស័យនេះ និងជាប្រយោជន៍ ដល់ប្រជាជនកម្ពុជា ព្រមទាំង សំណូមពរឱ្យមានការបណ្តុះបណ្តាល ពលករ និងវិស្វករកម្ពុជាបន្ថែមទៀត។ ក្នុងឱកាស នោះដែរ ថ្នាក់ដឹកនាំក្រុមហ៊ុន **ហ័រវ៉េ** ក៏បានបង្ហាញពីទិដ្ឋភាពទូទៅនៃបរិវេណទីស្នាក់ការកណ្តាលនេះដែលគ្របដណ្តប់ លើផ្ទៃដីប្រមាន ១.៥៣៦ គីឡូម៉ែតក្រឡា ហើយដោយឡែកគឺ កន្លែង Showroom នៃឧបករណ៍ទំនើបៗដែល ក្រុមហ៊ុនផលិតបាន ឃ្លាំងផ្គត់ផ្គង់ទំនិញចេញរបស់រោងចក្រ មជ្ឈមណ្ឌលផ្ទុកទិន្ន័យ និងកន្លែងស្នាក់នៅសំរាប់ បុគ្គលិកប្រមាណ ៣.000នាក់។